ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៦ សសរ

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតគណៈកម្មាធិការ
# ត្រួតពិនិត្យការអនុវត្តលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល

************

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## សម្រេច

### ប្រការ ១

ត្រូវបានបង្កើតគណៈកម្មាធិការត្រួតពិនិត្យ ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាលហៅកាត់ថា “ គ.ត.អ.ល.” ។ គ.ត.អ.ល. ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ។

### ប្រការ ២

គ.ត.អ.ល. មានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្ដម ឃឹម បូរ | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្ដម ឆេង សាឿន | រដ្ឋលេខាធិការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ | អនុប្រធាន |
| ៣-ឯកឧត្ដម កែវ សាផល | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤-ឯកឧត្ដម ប៉ាល់ ចន្ទតារា | មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ៥- ឯកឧត្ដម សួរ គីមអាន | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | សមាជិក |
| ៦- ឯកឧត្ដម លឹម អេង | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |

| | | |
|---|---|---|
| ៧- ឯកឧត្តម ឈួរ ស្រីឬទ្ធិ | អគ្គនាយកអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៨- លោក ទូច សារិន | ប្រធាននាយកដ្ឋានរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩- លោក ស៊ឹម សាន | ប្រធាននាយកដ្ឋានពាណិជ្ជកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០- លោក ឃុយ ហៀង | ប្រធាននាយកដ្ឋានគមនាគមន៍ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១- លោក ឡុង សុខា | ប្រធាននាយកដ្ឋានកសិកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២- លោក អ៊ុត ស៊ីណាត | ប្រធានផ្នែកទទួលបន្ទុកសំណួរ-ចម្លើយសភា នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១៣- លោក ជ្រុក ចាន់ណារិទ្ធ | ប្រធាននាយកដ្ឋានទំនាក់ទំនងអធិការកិច្ចតាមបណ្តាស្ថាប័ននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១៤- លោក ឡុក ស៊ីណា | អនុប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១៥- លោក បាក់ ប៉េងអ៊ុយ | អនុប្រធាននាយកដ្ឋានតាមដានការអនុវត្តច្បាប់ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១៦- លោក ហេង ចាន់ឌី | អនុប្រធាននាយកដ្ឋានអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១៧- លោក ឆៃ វ៉ាន់ឆន | អនុប្រធាននាយកដ្ឋានឧស្សាហកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៨- លោក ឆា លាងហ៊ីត | ជំនួយការអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល និងជាប្រធានលេខាធិការដ្ឋាន | សមាជិក |

## ប្រការ ៣

គណៈកម្មាធិការនេះមានតួនាទី ជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងកាត្រួតពិនិត្យការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រចតុកោណជំហានទី ២ និងមានភារកិច្ចដូចតទៅ ៖

-ធ្វើបញ្ជីសម្រង់រាល់លិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល

-តាមដានពិនិត្យការអនុវត្ត អនុក្រឹត្យ បទបញ្ជា សេចក្តីសម្រេច សារាចរ របស់រាជរដ្ឋាភិបាល និង សេចក្តីសម្រេច នៃ សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដោយសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីរកឱ្យ ឃើញចំណុចខ្លាំង ចំណុចខ្សោយនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តទាំងនោះ

-កោះអញ្ជើញតំណាងក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ មកបំភ្លឺការអនុវត្តលិខិតបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាល

-ចុះពិនិត្យតាមដានដល់មូលដ្ឋានពាក់ព័ន្ធទៅនឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលក្នុងករណីចាំបាច់

-ទទួលភារៈកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល ។

## ប្រការ ៤

គ.ត.អ.ល. មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ គ.ត.អ.ល. មានសិទ្ធិរៀបចំក្រុមការងារដើម្បីចុះបំពេញភារកិច្ចតាមការចាំបាច់ និងមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធចូលរួមក្នុងប្រតិបត្តិការ ។

## ប្រការ ៥

សមាជិក គ.ត.អ.ល. ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

## ប្រការ ៦

គ.ត.អ.ល. មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាជំនួយការដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ។ លេខាធិការដ្ឋាននេះដឹកនាំដោយប្រធានមួយរូប និងមានមន្ត្រីក្របខ័ណ្ឌរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចមួយចំនួន ជាជំនួយការតាមការចាំបាច់របស់ គ.ត.អ.ល. ។

## ប្រការ ៧

សេចក្តីសម្រេចលេខ ៣៦ សសរ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមការងារសម្រាប់ត្រួតពិនិត្យឃ្លាំមើលទៅលើសកម្មភាពនិងលទ្ធផលអនុវត្តការងាររបស់ក្រសួង ស្ថាប័ន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

## ប្រការ ៨

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី ខេត្ត ក្រុង ពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងខាងក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទការល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៨
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ